## សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

សូមជូន

បទបង្ហាញអំពីការប្រើប្រាស់

# "ជំណាកឃ្លា" នៅក្នុងភាសាខ្មែរ


បង្ហាញជូនដោយៈ ឈួរ អាង (សមាជិកស្ថាបនិកនៃសមាគម)

គេហទំព័រៈ www.khmerntech.org

អាសយដ្ឋានអ៊ីម៉ែលៈ info@khmerntech.org លេខទូរស័ព្ទៈ ០៩២ ៩៦៩៣៣៣

# សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

## អំពីសមាគម

**សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា** ជាសមាគមនៃអ្នកស្ម័គ្រចិត្តដែលមានទឹកចិត្តស្រឡាញ់ រក្សា និងអភិវឌ្ឍជានិរន្តន៍នៃភាសានិងអក្សរសាស្ត្រខ្មែរដោយចូលរួមជំរុញឱ្យមានការប្រើប្រាស់ភាសាខ្មែរឱ្យបានត្រឹមត្រូវនិងទូលំទូលាយ។ គេហទំព័រ៖ www.khmerntech.org សារអេឡិចត្រូនិច: info@khmerntech.org

ក្រោម ស្លោ កថា "រីករាយ នឹងភាសា ខ្មែរ នៅ ក្នុងពិភពឌីជីថល" សមាគមបាន ខិតខំបង្កើតឱ្យមានសៀវភៅអេឡិចត្រូនិចជាភាសាខ្មែរ(តាមស្តង់ដារយូនីកូដ)ដែលជាប្រភេទសៀវភៅអាចឱ្យលោកអ្នកបើកអាននៅលើឧបករណ៍អេឡិចត្រូនិចដូចជា **ឧបករណ៍អានសៀវភៅអេឡិចត្រូនិច កុំព្យូទ័រ ទូរស័ព្ទវៃឆ្លាត និងផែនចារឹក**...ដែលបើកអានដូចជាសៀវភៅពិតៗយ៉ាងដូច្នេះដែរ។ ការណ៍នេះបានធ្វើឱ្យអក្សរខ្មែរបានជ្រាបចូលក្នុងបច្ចេកវិទ្យាមួយកម្រិតថែមទៀតដូចភាសានានាដែរ។

**គម្រោងបច្ចុប្បន្នកំពុងដំណើរការ**

១) គម្រោងធ្វើសៀវភៅអេឡិចត្រូនិចជាភាសាខ្មែរតាមទម្រង់.ePub
២) គម្រោងបង្កើតកម្មវិធីអានសៀវភៅអេឡិចត្រូនិចដំណើរការលើទូរស័ព្ទវៃឆ្លាត
៣) គម្រោងបង្កើតគេហទំព័រពាណិជ្ជកម្មដាក់លក់សៀវភៅអេឡិចត្រូនិច

# សមាគមភាសាខ្មែរនិងភាសាខ្មែរ

## "ដំណាក់ឃ្លា" នៅក្នុងភាសាខ្មែរ

### មាតិកា

១) និយមន័យ
២) ដំណាក់ឃ្លានិងចន្លោះពាក្យ
៣) ដំណាក់ឃ្លានិង "ដែល"
៤) ដំណាក់ឃ្លានិងប្លង់នៃការរៀបរាប់
៥) ដំណាក់ឃ្លានិងជម្លោះសម្ព័ន្ធ
៦) ដំណាក់ឃ្លានិងឈ្មោះ
៧) ដំណាក់ឃ្លានិងវណ្ណវាទ
៨) ដំណាក់ឃ្លានិងកាលបរិច្ឆេទ
៩) ដំណាក់ឃ្លានិងឈ្នាប់ "និង"
១0) ក្រឡេកមើលការប្រើប្រាស់សព្វថ្ងៃ

## ១) និយមន័យ

"**ដំណាកឃ្លា**" ជាសុញ្ញដ្ឋានឬជាគម្លាតមួយឯកតារវាងធាតុពីរ ហើយមានមុខងារសម្ព័ន្ធច្បាស់លាស់និងមានតួនាទីជាចលករនៃការស្ថាបនាន័យនៃឯកតាភាសាមួយ។

ដំណាកឃ្លាមានតួនាទីយ៉ាងសំខាន់ក្នុងយន្តការនៃការស្ថាបនាន័យក្នុងភាសាខ្មែរ។ ថ្វីត្បិតតែគ្មានរូបតាងដោយគំនូស ដូចធាតុផ្សេងៗទៀតនៃភាសាក៏ដោយ ក៏ដំណាកឃ្លាមានវត្តមាននៅគ្រប់កម្រិតវាទកម្មហើយបង្ហាញនូវបរិបទនៃការប្រើប្រាស់ជំសម្បូរបែប។

## ២) "ដំណកឃ្លា"និង"ចន្លោះពាក្យ"

នៅក្នុងបរិបទខ្លះ សំណេរនៃសំណុំពាក្យមិនត្រូវបានបែងចែកដោយដំណកឃ្លានោះទេ វានឹងមានន័យផ្សេងទៅវិញប្រសិនបើសំណុំពាក្យនោះត្រូវបានបែងចែកឱ្យដាច់ពីគ្នាដោយដំណកឃ្លា។

ឧទាហរណ៍៖ "បងប្អូន" វាខុសពី "បង ប្អូន"(បងនិងប្អូន)

១) តារាជាបងប្អូនខ្ញុំ (តារាអាចជាបង ជាប្អូន ឬជាប្អូនជីដូនមួយ....)

២) តារាជាបង ប្អូនខ្ញុំ (តារាមិនអាចជាបង ហើយជាប្អូនបាននោះទេ)

សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

## ៣) "ដំណាកឃ្លា"និង"ដែល"

នៅក្នុងបរិបទនេះ សំណេរដែលមានដំណាកឃ្លានៅពីមុខនិងពីក្រោយ "ដែល" អាចបង្កើតឱ្យមានបំណាកស្រាយន័យផ្សេងៗគ្នាដែរ។

ឧទាហរណ៍៖

១) ដំណាកឃ្លា ជាសុញ្ញដ្ឋានឬជាគម្លាតរវាងធាតុពីរ**ដែល**មានមុខងារសម្ព័ន្ធច្បាស់លាស់។

២) ដំណាកឃ្លា ជាសុញ្ញដ្ឋានឬជាគម្លាតរវាងធាតុពីរ **ដែល**មានមុខងារសម្ព័ន្ធច្បាស់លាស់។

**៤) "ដំណកឃ្លា"និង"ប្លង់នៃការរៀបរាប់"**

នៅក្នុងប្លង់វាទកម្មដែលមានការរៀបរាប់ធាតុចាប់ពីពីរឡើងទៅ តម្រូវឱ្យមាន "ដំណកឃ្លា"មួយនៅចន្លោះពាក្យនីមួយៗ។ ការភ្ជាប់ដំណកឃ្លាក្នុងបរិបទនេះ បង្កើតឱ្យមានបញ្ហាខាងផ្នែកកម្រិតសម្ព័ន្ធ។ យន្តការនៃ"**ដំណកឃ្លា**"នេះ ប្រព្រឹត្តទៅ នៅ ក្នុងរង្វង់នៃការរៀបរាប់ ហើយគ្មានវិសាលកម្មទៅលើធាតុផ្សេងទៀតដែលនៅក្រៅប្លង់វាទកម្មនេះឡើយ លើកលែងតែមានករណីពិសេសដោយឡែកណាមួយជាយថាហេតុ។

ឧទាហរណ៍៖

១) កសិករចិញ្ចឹមគោ ក្របី សេះ ។ល។

២) កសិករចិញ្ចឹម គោ ក្របី សេះ ។ល។

៣) ដែក ទង់ដែង ស័ង្កសី សំណ សុទ្ធតែលោហធាតុ។

៤) តើដែក ទង់ដែង ស័ង្កសី សំណ ជាលោហធាតុមែនទេ?

៥) ដែក ទង់ដែង ស័ង្កសី សំណ ជាលោហធាតុ ចំណែកឯ ជ័រ កៅស៊ូ ឈើ មិនមែនជាលោហធាតុទេ។

Khmer and Technology

# សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

## ៤) "ដំណកឃ្លា"និង"ជម្លោះសម្ព័ន្ធ"

ដំណកឃ្លា មានតួនាទីយ៉ាងសំខាន់ក្នុងផ្នែកសម្ព័ន្ធនិងការស្ដាបនាន័យ។ ឧទាហរណ៍ខាងក្រោមនេះនឹងរំលេចឡើងអំពីជម្លោះប្រសិនបើមានឬគ្មានដំណកឃ្លា។

ឧទាហរណ៍៖

១) ពេលកើតហេតុ តើមានវត្តមានលោកនៅទីនោះដែរឬទេ?

២) មានវត្ត មានលោក វាជារឿងធម្មតា តែបើមានវត្ត គ្មានលោកវិញ ទើបជារឿងចម្លែក។

## ៤) "ដំណកឃ្លា"និង"វណ្ណវាទ"

វណ្ណវាទមួយចំនួន ដូចជា សញ្ញាខណ្ឌ( ។) សញ្ញាសួរ( ? ) សញ្ញាឧទាន( ! ) សញ្ញាក្បៀស ( , ) សញ្ញាដំពីរ( ៖ ) សញ្ញាគំនូស( - ) ជាដើម មានការជាប់ទាក់ទងនឹងដំណកឃ្លា។ វណ្ណវាទ ជាប្រភេទមួយនៃសិប្បសញ្ញា ហើយមានលក្ខណៈខុសពី "វណ្ណយុត្ត" ព្រោះ "វណ្ណយុត្ត" មាន តួនាទីប្រកបសូរ ឯ"វណ្ណវាទ "វិញ គ្មានតួនាទីប្រកបសូរទេ តែ មានវិសាល កម្មក្នុងផ្នែក សម្ព័ន្ធ។

ឧទាហរណ៍៖

សញ្ញាខណ្ឌ( ។) ជាធាតុមួយនៃឃ្លា ដែលមានលក្ខណៈដូចពាក្យនីមួយៗដែរ ហើយការចងសម្ព័ន្ធដើម្បីបង្កើតជាឃ្លា វាមិនតម្រូវឱ្យមានដំណកឃ្លានៅចន្លោះធាតុទាំងនោះទេ។ ហេតុនេះ យើងមិនត្រូវដាក់ដំណកឃ្លានៅមុខសញ្ញាខណ្ឌ( ។)ឡើយ។ ប៉ុន្តែ នៅក្រោយសញ្ញាខណ្ឌ ដំណកឃ្លានេះត្រូវតែមានជាដាច់ខាត ព្រោះវាជាទីតាំងដែលមានការចាប់ផ្តើមនៃឃ្លាថ្មី។

ក្នុងក្របខ័ណ្ឌនេះ សញ្ញាវណ្ណវាទផ្សេងៗទៀត ក៏ត្រូវប្រើដំណកឃ្លាតាមទម្រង់នេះដែរ។

## ៤) "ជំណាកឃ្លា"និង"កាលបរិច្ឆេទ"

ការប្រើជំណាកឃ្លា មិនត្រូវប្រាសចាកពីការចងសម្ព័ន្ធនិងកម្រិតវាទកម្មនៃឃ្លាឡើយ។ ឧទាហរណ៍ខាងក្រោមនេះនឹងឆ្លុះបញ្ចាំងការប្រើប្រាស់មិនឯកភាពគ្នាដែលនៅតែមានរហូតដល់សព្វថ្ងៃ។

ឧទាហរណ៍៖

១) ធ្វើនៅភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧។
២) ធ្វើនៅភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧។
៣) ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧។

៤) "ដំណកឃ្លា"និងឈ្នាប់"និង"

**ក) ករណីគ្មានដំណកឃ្លានៅសងខាងឈ្នាប់៖** ក្នុងករណីដែលធាតុពីរត្រូវបានចងភ្ជាប់ដោយ ឈ្នាប់ "និង"គេមិនត្រូវប្រើ"ដំណកឃ្លា នៅពីមុខនិងពីក្រោយ ឈ្នាប់ "និង"ទេ ត្បិតអីធាតុទាំងពីរនេះនិងឈ្នាប់"និង"បានចូលរួមអន្តរកម្មជាមួយគ្នាក្នុងផ្នែកសម្ព័ន្ធ ដើម្បីបង្កើតជា កន្សោម មួយដែលមួយដែលធាតុទាំងពីរមិនអាចកាត់ផ្ដាច់ចេញពីគ្នាបាន ដោយ ដំណកឃ្លាឡើយ។ ម៉្យាង ទៀតធាតុនីមួយៗដែលចងភ្ជាប់ដោយ "និង"ស្ថិតនៅក្នុងកម្រិតវាទកម្មតែមួយ។

ឧទាហរណ៍៖

១) គាត់ចេះភាសាបារាំងនិងអង់គ្លេស។

២) គាត់ចេះភាសាបារាំង និងអង់គ្លេស។

# សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

## ៤) "ដំណកឃ្លា"និងឈ្នាប់"និង" (ត)

**ខ)ដំណកឃ្លានៅមុខឈ្នាប់៖** ក្នុងករណីដែលមានការពង្រាយធាតុចាប់ពីពីរឡើងទៅនៅក្នុងប្លង់នៃការរៀបរាប់ ដែលធាតុនីមួយៗស្ថិតនៅក្នុងកម្រិតវាទកម្មស្មើគ្នានោះ តម្រូវឱ្យមានដំណកឃ្លានៅចន្លោះធាតុជានិច្ច។ ជាទូទៅ "និង" ត្រូវស្ថិតនៅដើមទីតាំងនៃធាតុមួយដែលត្រូវបានទទួលឋានៈជាធាតុចុងក្រោយនៃការរៀបរាប់។

ឧទាហរណ៍៖

១) គាត់ចេះភាសាបារាំង អង់គ្លេស និងជប៉ុន។

២) គាត់ចេះភាសាបារាំង អង់គ្លេស និង ជប៉ុន។

៣) គាត់ចេះភាសាបារាំង ភាសាអង់គ្លេស និងភាសាជប៉ុន។

៤) គាត់ចេះភាសា បារាំង អង់គ្លេស និងជប៉ុន។

## ៤) "ជំណាកឃ្លា"និងឈ្នាប់"និង" (ត)

**គ) ជំណាកឃ្លានៅសងខាងឈ្នាប់៖** ក្នុងករណីជំណាកឃ្លាអាចកើតឡើងពីប្លង់វាទកម្មនៃការសង្កត់ន័យនិងរំលេចនូវកន្សោមពីរដែលមានតម្លៃដោយឡែកហួសពីព្រំដែននៃធាតុដែលបានចងសម្ព័ន្ធនឹងគ្នាតាមរយៈឈ្នាប់ "និង"។

ឧទាហរណ៍៖

១) នៅក្នុងគម្រោងស្នើសុំ សូមបញ្ជាក់ពីឈ្មោះសម្ភារៈដែលត្រូវទិញ និង ត្រូវបញ្ជូនគម្រោងនេះទៅការិយាល័យគណនេយ្យឱ្យបានមុនថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤។

២) រដ្ឋាភិបាលអាមេរិក និង សង្គ្រាមនៅអ៊ីរ៉ាក់៖ ការជាប់ផុងដែលមិនអាចដកខ្លួនរួចបាន។

៣) ការរៀបការ និង សេចក្តីស្នេហា ជារឿងពីរផ្សេងពីគ្នា។

Khmer and Technology

# សមាគមភាសាខ្មែរនិងបច្ចេកវិទ្យា

## ៤) "ដំណាក់ឃ្លា"និងឈ្នាប់"និង" (ត)

### គ) ដំណាក់ឃ្លានៅសងខាងឈ្នាប់៖ (ត)

ឧទាហរណ៍៖

១) ការជ្រើសរើសសម្លៀកបំពាក់ និង ថ្ងៃរៀបការ ជារឿងពីរផ្សេងគ្នា។

២) ថ្ងៃរៀបការ និង ការជ្រើសរើសសម្លៀកបំពាក់ ជារឿងពីរផ្សេងពីគ្នា។

៣) ថ្ងៃរៀបការ និង ការជ្រើសរើសសម្លៀកបំពាក់ជារឿងពីរផ្សេងគ្នា។

## ៤) "ដំណាក់ឃ្លា"និងឈ្នាប់"និង" (តចប់)

### គ) ដំណាក់ឃ្លានៅសងខាងឈ្នាប់៖ (តចប់)

ឧទាហរណ៍៖

១) ការជ្រើសរើសសម្លៀកបំពាក់និងថ្ងៃរៀបការជារឿងដែលយើងត្រូវគិតគូរឱ្យបានល្អិតល្អន់។

២) ការជ្រើសរើសសម្លៀកបំពាក់និងថ្ងៃរៀបការ ជារឿងដែលយើងត្រូវគិតគូរឱ្យបានល្អិតល្អន់។

៣) ការជ្រើសរើសសម្លៀកបំពាក់និងការជ្រើសរើសថ្ងៃរៀបការជារឿងដែលយើងត្រូវគិតគូរឱ្យបានល្អិតល្អន់។

៤) ថ្ងៃរៀបការនិងការជ្រើសរើសសម្លៀកបំពាក់ជារឿងដែលយើងត្រូវគិតគូរឱ្យបានល្អិតល្អន់។

ចប់ដោយសង្ខេប

សូមអរគុណ!

ក្រឡេកមើលការប្រើប្រាស់ដំណកឃ្លសព្វថ្ងៃ
នៅលើគេហទំព័រសាព័ត៌មាននានា